## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ រយៈពេល ៣ ឆ្នាំ (២០១៩ - ២០២១)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | បារ៉ាយរុងរឿង |
| ភូមិ | ៖ | បារ៉ាយ ច្រវ៉ាក់ដែក ក្របីក្រៀក |
| ឃុំ | ៖ | ឈូក |
| ស្រុក | ៖ | ក្រូចឆ្មារ |
| ខេត្ត | ៖ | ត្បូងឃ្មុំ |

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ រយៈពេល ៣ ឆ្នាំ (២០១៩ - ២០២១)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | បារ៉ាយរុងរឿង |
| ភូមិ | ៖ | បារ៉ាយ ច្រវ៉ាក់ដែក ក្របីក្រៀក |
| ឃុំ | ៖ | ឈូក |
| ស្រុក | ៖ | ក្រូចឆ្មារ |
| ខេត្ត | ៖ | ត្បូងឃ្មុំ |

# មាតិកា

## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១. ស្ថានភាពទូទៅ** ........ 1

**២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** ........ 2

ក- ប្រជាសាស្ត្រ ........ 2

ខ- មុខរបរ ........ 2

**៣. កន្លែងនេសាទសហគមន៍**
**និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ 2

ក- ទីតាំង ........ 2

ខ- ដែននេសាទ ........ 3

គ- តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ 3

ឃ- ធនធានជលផល ........ 3

**៤. ការធ្វើនេសាទ** ........ 4

ក- អ្នកនេសាទ ........ 4

ខ- ឧបករណ៍នេសាទ ........ 4

គ- ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ ........ 6

**៥. ផែនការគ្រប់គ្រងសហគមន៍នេសាទ** ........ 6

ក- ទស្សនៈវិស័យ ........ 6

ខ- គោលបំណង ........ 6

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ 6

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ 6

គ២-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ 9

គ៣-ផែនការគ្រប់គ្រងព្រៃលិចទឹក ........ 10

គ៤-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ 11

គ៥-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ 11

គ៦-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល ........ 12

គ៧-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ ........ 12

ឃ- ផែនការយុទ្ធសាស្ត្រ ........ 14

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បារ៉ាយរុងរឿង រយៈពេល ៣ឆ្នាំ (២០១៩ដល់២០២១)** ........ 15

**តារាងកម្មវិធីការងារ** ........ 19

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទបាវ៉ាយរុងរឿងបានកកើតឡើងនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៤ ដោយមានការសម្រប សម្រួលពីខណ្ឌរដ្ឋបាលជលផលកំពង់ចាម និងមានការឧបត្ថម្ភគាំទ្រពីអង្គការវីជីឡែន។ បន្ទាប់មក ដោយអនុវត្តតាម អនុក្រឹត្យលេខ២៥អនក្រ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទរបស់រាជរដ្ឋាភិបាល កម្ពុជា និងប្រកាសលេខ៣១៦ប្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហ-គមន៍នេសាទរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយនិងមានការឧបត្ថម្ភគាំទ្រពីនាយកដ្ឋានអភិវឌ្ឍន៍ សហគមន៍នេសាទនៃរដ្ឋបាលជលផលសហការជាមួយខណ្ឌរដ្ឋបាលជលផលកំពង់ចាម និងអាជ្ញាធររដ្ឋបាលភូមិ ឃុំ ឈូក ទើបសហគមន៍នេសាទបាវ៉ាយរុងរឿងបានរៀបចំមហាសន្និបាតកំណើតលើកដំបូង នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៨ ហើយបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

សហគមន៍នេសាទបាវ៉ាយរុងរឿងមានទីតាំងស្ថិតនៅក្នុងភូមិបាវ៉ាយ ច្រវ៉ាក់ដែក និងក្របីក្រៀក ឃុំឈូក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ មានសមាជិកសហគមន៍នេសាទសរុបចំនួន២៤១នាក់ ប្រុសចំនួន២១៨ និងស្រីចំនួន ២៣នាក់ ក្នុងនោះចំនួនគ្រួសារសរុបចំនួន២៤១គ្រួសារ ដែលមានគណៈកម្មការសហគមន៍នេសាទចំនួន១១នាក់ ស្រី០១នាក់ និងមានក្រុមល្បាតចំនួន៣២នាក់ ដោយចែកជា៣ក្រុម។

កន្លងមកសហគមន៍នេសាទនេះ បានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន៖

- រៀបចំធ្វើមហាសន្និបាតបង្កើតសហគមន៍នេសាទ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ និងបង្កើតក្រុមល្បាត
- រៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- កំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍
- រៀបចំធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- បង្កើតកន្លែងអភិរក្សត្រីមេពូជនៅក្នុងព្រែកជីឡែង
- ចុះល្បាត តាមដាន និងទប់ស្កាត់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍
- ស្នើសុំចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណកម្មការសហគមន៍នេសាទ
- ចូលរួមប្រជុំជាមួយអាជ្ញាធររដ្ឋបាលភូមិ ឃុំ
- ប្រមូលព័ត៌មានទូទៅសម្រាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក- ប្រជាសាស្ត្រ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទ ៣៧៣៧នាក់ ប្រុស ១១២៥នាក់ ស្រី ២០១២នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន៣០២៥នាក់ ខ្មែរឥស្លាម ៧១២នាក់ និងអាណិកជនវៀតណាមគ្មាន។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៧៧នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៨នាក់ ស្រី ២នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ១៦នាក់ ស្រី ៦នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ៦៨នាក់ ស្រី ៣៩នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍អ្នកកាន់សាសនាព្រះពុទ្ធ ៨១%។ ក្រៅពីនេះមានអ្នកកាន់សាសនាអ៊ីស្លាម ប្រមាណ ១៩% សាសនាកាតុលិកប្រមាណ គ្មាន។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរចំនួន៧៥៨នាក់ ស្រី ៣៤៧នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន ៥៩៥នាក់ ស្រី ៣៨៣នាក់ និងកម្រិតមធ្យមសិក្សាចំនួន ៥៤នាក់ ស្រី ៣៣នាក់ និងកម្រិតថ្នាក់ឧត្តមសិក្សាចំនួន ៨នាក់ ស្រី ៣នាក់ ។

ខ- មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

| | |
|---|---|
| - ធ្វើនេសាទចំនួន | ៥៥គ្រួសារ |
| - ធ្វើស្រែចំនួន | ៣៥០គ្រួសារ ទំហំផ្ទៃដី៩៧០ហិកតា |
| - ធ្វើវារីវប្បកម្មចំនួន | ៣៧គ្រួសារ ចំនួន ៣៧បែ |
| - ជាងផ្ទះចំនួន | ១៥គ្រួសារ |
| - ធ្វើចំការចំនួន | ៩៣០គ្រួសារ ទំហំផ្ទៃដី ២៧៩០ហិកតា |
| - ចិញ្ចឹមសត្វចំនួន | ៣៧គ្រួសារ |
| - លក់ដូរចំនួន | ៣៥គ្រួសារ |
| - កម្មករចំនួន | ១៣៩គ្រួសារ |
| - មន្ត្រីរាជការចំនួន | ១៣គ្រួសារ |

- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំ មានចំនួន៧.៣០០.០០០រៀល។

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

ក- ទីតាំង

កន្លែងនេសាទសហគមន៍បារ៉ាយរុងរឿងជាកន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទ ជាប្រពៃណីក្នុងដែននេសាទទឹកសាប មានទំហំ២៤៩៩ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់និងឃុំជីនិត ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ
- ខាងត្បូងទល់និងភូមិបារ៉ាយ ឃុំឈូក ស្រុកក្រូចឆ្មារ
- ខាងកើតទល់និងឃុំសេដា ស្រុកដំបែរ ខេត្តត្បូងឃ្មុំ
- ខាងលិចទល់និងភូមិឈូក ឃុំឈូក ស្រុកក្រូចឆ្មារ

ខ- ដែននេសាទ,

កន្លែងនេសាទសហគមន៍**បារ៉ាយរុងរឿង** មានបឹងចំនួន០៣ ព្រែកចំនួន០២ ប្រឡាយចំនួន០១ ទំនាបលិចទឹកក្នុងរដូវជំនោរឡើង និងនាទីព្រៃលិចទឹក គឺ៖

- បឹងស្អក មានទំហំប្រហែល ៣ហិកតា នេសាទពេញមួយឆ្នាំ
- បឹងប្រម៉ាត់ដី មានទំហំប្រហែល ២ហិកតា នេសាទពេញមួយឆ្នាំ
- បឹងកណ្ដោ(ក្ដិ) មានទំហំប្រហែល៨០ហិកតា នេសាទពេញមួយឆ្នាំ
- ព្រែកផុក មានបណ្ដោយប្រហែល១៥០០ម៉ែត្រ និងទទឹងប្រវែង៤០ម៉ែត្រ នេសាទពេញមួយឆ្នាំ
- ព្រែកជីឡែង មានបណ្ដោយប្រហែល១៧០០ម៉ែត្រ និងទទឹងប្រវែង៧០ម៉ែត្រ នេសាទពេញមួយឆ្នាំ
- ប្រឡាយកណ្ដោ មានបណ្ដោយប្រហែល១៧៥០ម៉ែត្រ និងទទឹងប្រវែង៥ម៉ែត្រ នេសាទពីខែកក្កដា ដល់ខែវិច្ឆិកា រៀងរាល់ឆ្នាំ
- ទំនាបលិចទឹកក្នុងរដូវជំនោរឡើង និងនាទីព្រៃលិចទឹក មានទំហំប្រហែល ២៣៩៥ហិកតា។

គ- តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

- ព្រែកជីឡែង មានទំហំ ០១ហិកតា (បណ្ដោយ ២០០ម៉ែត្រ និងទទឹង៥០ម៉ែត្រ)។

ឃ- ធនធានជលផល

- ប្រភេទត្រី (ត្រីឆ្ដោ ត្រីប្រា ត្រីពោ ត្រីរ៉ស់ ត្រីឆ្លាំង ត្រីកែស ត្រីក្រម៉ម ត្រីតាអោន ត្រីក្អែក ត្រីក្រឡង់ ត្រីសណ្ដាយ ត្រីអណ្ដែង ត្រីដំរី ត្រីឆ្លូញ ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្នឹង ត្រីកញ្ជនជ័យ ត្រីខ្មាន់ ត្រីឈ្វៀត ត្រីកញ្ជ្រូក ត្រីបណ្ដូលអំពៅ ត្រីច្រកែង ត្រីកាហែ ត្រីក្រាយ ត្រីខ្នឹង ត្រីព្រួល ត្រីទ្រនេន ត្រីក្រសក់ ត្រីគល់រាំង ត្រីកន្ធ្រប ត្រីកន្ធ្របខ្លា ត្រីកញ្ចុះ ត្រីលិញ ត្រីក្រាញ់ ត្រីចង្វា ត្រីផ្ទោង ត្រីអាចម៍កុក ត្រីស្លឹកឬស្សី ត្រីក្លាំងហាយ ត្រីកន្ធរ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រកាក្ដាម ត្រីលលកសរ ត្រីឆ្ពិន ត្រីបណ្ដូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ចាញ់ច្រាស់ ត្រីកំភ្លាញ កំពឹស បង្កង,.....។ល។)
- ប្រភេទវារីសត្វ (ពស់ ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងមាស(ខ្យងពណ៌លឿង) ខ្ទៅ លៀស គ្រំប៉ោក គ្រំចំពុះទា ក្ដាម អន្ទង់ កង្កែប អណ្ដើក កន្ធាយ ភេ,......។ល។
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ (ដើមរាំង ភ្នំភ្លេង ប្របួយមេ ប្របួយឈ្មោល ថ្លើមអណ្ដើក អូយយ៉ាស់(បន្លាយយួន) អញ្ចាញ កន្ទ្រែង ស្មែងក្របី ស្នូលទឹក ច្រកែង ប្រផេញ ផ្ដៅ ភ្អែកព្រាប បាក់ដង

កន្ទៀវ ផ្ទេញត្រីញី ទៀនព្រៃ ត្រស់ ថ្វាង ត្លូ ខ្ទាយមាន់ វល្លិ៍ប្រេង វល្លិ៍ទឹកដោះ វល្លិ៍ត្រដិត វល្លិ៍ ដោះគន់ វល្លិ៍ត្រី វល្លិ៍ត្អើក ល្ពាក់ទឹក ស្លាបទា កន្ទាំងហៃ រញា ស្មៅ ស្លត់ បន្លាឃ្លេ ផ្តៅល ថ្វាន់ ត្រដក់ កន្ទុយអន្ទង់ ពោះក្អម ត្រកួន ព្រលិតអាចមន៍មាន់ ព្រលិតដូង រំចង់ ស្តន់អំបោះ ត្រាវអណ្តែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំបួង កក់ជ្រុង កក់ក្តាម ឈូក ចន្ទល់ភ្នំ(វល្លិ៍ថ្កាល់ត្រី) កញ្ជែត ស្មៅថ្នក់ទឹក ស្តន់ដំរី វល្លិ៍អណ្តាតត្រកួត ក្រចាប់ សារាយ កំប្លោក ចកតូច ចកធំ កំពីងពួយស កំពីងពួយក្រហម ។ល។)

## ៤. ការធ្វើនេសាទ

### ក- អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១៩៥នាក់ ស្រី៥នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន៤៦នាក់ ស្រី១៨នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៤៣៥នាក់ ស្រី៤៦នាក់

### ខ- ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូករបស់សមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ៨៧ | ១៥០ម-២០០ម/គ្រួសារ | ១៥៦៦០ម៉ែត្រ | ពេញមួយឆ្នាំ |
| អួនផ្តែផ្តួត(ថ្នងអូស) | ម៉ែត្រ | ៤ | ៣០ម៉ែត្រ/គ្រួសារ | ១២០ម៉ែត្រ | ខែធ្នូ-ខែឧសភា |
| សន្ទូចរនង | ផ្លែ | ៣០ | ២០០-៣០០ផ្លែ / គ្រួសារ | ៩០០០ផ្លែ | ខែវិច្ឆិកា-ខែមករា |
| លប | គ្រឿង | ៣០ | ៤០-៦០គ/គ្រួសារ | ១៥០០គ្រឿង | ពេញមួយឆ្នាំ |
| លាន់ | គ្រឿង | ១០ | ៥០គ្រឿង/គ្រួសារ | ៥០០គ្រឿង | ខែកញ្ញា-ខែវិច្ឆិកា |
| សំណាញ់ | វង់ | ៦ | ១វង់/គ្រួសារ | ៦វង់ | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៣០គ្រឿង | ២០០-៥០០គីឡូក្រាម | ៦,៥-១៣សេះ |
| ទូកអុំ និងចែវ | ៥៥គ្រឿង | ៥០-១០០គីឡូក្រាម | |

- ឧបករណ៍នេសាទ និងទូករបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ៥០ | ១៥០ម-២០០ម/គ្រួសារ | ៩០០០ម៉ែត្រ | ពេញមួយឆ្នាំ |
| អួនផ្ដេកឆ្នូត(ថ្នងអូស) | ម៉ែត្រ | ៥ | ៣០ម៉ែត្រ/គ្រួសារ | ១៥០ម៉ែត្រ | ខែធ្នូ-ខែឧសភា |
| សន្ទូចរនង | ផ្លែ | ១៥ | ២០០-៣០០ផ្លែ / គ្រួសារ | ២៧០០ផ្លែ | ខែវិច្ឆិកា-ខែមករា |
| លប | គ្រឿង | ១២ | ៤០-៦០គ្រឿង/គ្រួសារ | ៦០០គ្រឿង | ពេញមួយឆ្នាំ |
| លាន់ | គ្រឿង | ១៥ | ៥០គ្រឿង/ គ្រួសារ | ៧៥០គ្រឿង | ខែកញ្ញា-ខែវិច្ឆិកា |
| សំណាញ់ | វង់ | ៥ | ១វង់/គ្រួសារ | ៥វង់ | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ២គ្រឿង | ២០០-៥០០គីឡូក្រាម | ៦,៥-១៣សេះ |
| ទូកអុំ និងចែវ | ២៥គ្រឿង | ៥០-១០០គីឡូក្រាម | |

- ឧបករណ៍នេសាទណនិងទូករបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ១៦០ | ១៥០ម-២០០ម/គ្រួសារ | ៣២០០០ម៉ែត្រ | ពេញមួយឆ្នាំ |
| សន្ទូចបង្កៃ | ផ្លែ | ៧៥ | ២០០-៣០០ផ្លែ / គ្រួសារ | ២២៥០០ផ្លែ | ខែវិច្ឆិកា-ខែមករា |
| សន្ទូចបបក់ | ផ្លែ | ៣៥ | ១ផ្លែ/គ្រួសារ | ៣៥ផ្លែ | ខែវិច្ឆិកា-ខែឧសភា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| គ្មាន | | | |
| គ្មាន | | | |

គ- ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចម្រុះ | ៥៤០គីឡូក្រាម | ៤៨០គីឡូក្រាម | ១០២០គីឡូក្រាម |
| វារីសត្វ (ខ្យង លៀស) | ៤៥០គីឡូក្រាម | គ្មាន | ៤៥០គីឡូក្រាម |

## ៥. ផែនការគ្រប់គ្រងសហគមន៍នេសាទ

ក- ទស្សនៈវិស័យ

សហគមន៍នេសាទ**បាវ៉ាយរុងរឿង**មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ- គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលជាកន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ទំនាបលិចទឹកក្នុងរដូវតំឡើង និងនាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍចម្រុះ ដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ និងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ប្រភេទឧបករណ៍អនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (ក្នុងពេលតែមួយ) | |
| ១.បឹងស្អក | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ៨០០០ម៉ែត្រ/ ៤០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/ ៤០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |

| | | | | | |
|---|---|---|---|---|---|
| | ធ្នូ-ឧសភា | អួនផ្តែផ្លូត | ៣០ម/គ្រួសារ | ២៤០ម៉ែត្រ/ ៨គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ខែមករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ១០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | លប | ៤០គ្រឿង/គ្រួសារ | ១០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ១០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ១៥គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ឧសភា | បបក់ | ផ្លែ/គ្រួសារ | ៨គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | សំណាញ់ | មិនកំណត់ | មិនកំណត់ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| ២.បឹងប្រម៉ាត់ដី | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ៥០០០ម៉ែត្រ/ ២៥គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៣៧៥០ម៉ែត្រ/ ២៥គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | ធ្នូ-ឧសភា | អួនផ្តែផ្លូត | ៣០ម/គ្រួសារ | ១៨០ម៉ែត្រ/ ៦គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ខែមករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៧គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | លប | ៤០គ្រឿង/គ្រួសារ | ៨គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ៧គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ១០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | សំណាញ់ | មិនកំណត់ | មិនកំណត់ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| ៣.បឹងកណ្តៀ | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ២០០០០ម៉ែត្រ/ ១០០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ១៥០០០ម៉ែត្រ/ ១០០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |
| | ធ្នូ-ឧសភា | អួនផ្តែផ្លូត | ៣០ម/គ្រួសារ | ៩០០ម៉ែត្រ/ ៣០គ្រួសារ | -សមាជិកស.ន -មិនមែនសមាជិកស.ន |

| | | | | | |
|---|---|---|---|---|---|
| | វិច្ឆិកា-ខែមករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | លប | ៤០គ្រឿង/គ្រួសារ | ៣០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ៦០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ឧសភា | បបក់ | ផ្លែ/គ្រួសារ | ៤០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ៤.ព្រែកផុក | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ១២០០០ម៉ែត្រ/<br>៦០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៩០០០ម៉ែត្រ/<br>៦០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | ធ្នូ-ឧសភា | អួនផ្កែឆ្កួត | ៣០ម/គ្រួសារ | ៤៥០ម៉ែត្រ/<br>១៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ខែមករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | លប | ៤០គ្រឿង/គ្រួសារ | ២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ២៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ឧសភា | បបក់ | ផ្លែ/គ្រួសារ | ១៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | សំណាញ់ | មិនកំណត់ | មិនកំណត់ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ៥.ព្រែកជីឡែង | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ១៦០០០ម៉ែត្រ/<br>៨០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ១២០០០ម៉ែត្រ/<br>៨០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | ធ្នូ-ឧសភា | អួនផ្កែឆ្កួត | ៣០ម/គ្រួសារ | ៦០០ម៉ែត្រ/<br>២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ខែមករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៣០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |

| | | | | | |
|---|---|---|---|---|---|
| | ពេញមួយឆ្នាំ | លប | ៤០គ្រឿង/គ្រួសារ | ៤០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ៥០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ៣០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ឧសភា | បបក់ | ផ្លែ/គ្រួសារ | ២៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | ពេញមួយឆ្នាំ | សំណាញ់ | មិនកំណត់ | មិនកំណត់ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ៦.ប្រឡាយកណ្តៅ | កក្កដា-វិច្ឆិកា | មងរាយ | ១០០ម/គ្រួសារ | ៥០០០ម៉ែត្រ/<br>៥០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កក្កដា-វិច្ឆិកា | លប | ៤០គ្រឿង/គ្រួសារ | ៧គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កក្កដា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ៨គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |

គ២-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) ត្រូវអភិរក្ស | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ស្មានតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ព្រែកជីឡែង (ប=១៧០០ម x ទ=៧០ម) | ១ហិកតា (ប=២០០ម x ទ=៥០ម) | អភិរក្សត្រីមេពូជ | បោះបង្គោលស៊ីម៉ងត៍ (7mX0.15mx0.15m) ចំនួន26ដើម ព័ទ្ធជុំវិញកន្លែងអភិរក្សមានទំហំ 1ហ.ត=200មX50ម) មានបរិមាត្រ 500ម៉ែត្រ ក្នុងចន្លោះ20ម៉ែត្របោះមួយបង្គោល។ | ៣១២០ | ១/៣/១៩ | ១/៥/២០ |
| | | | ធ្វើស្លាកសញ្ញាអភិរក្សចំនួន៤ផ្ទាំងដាក់នៅជាប់ព្រំប្រទល់កន្លែងអភិរក្ស | ៤០០ | ១/៤/១៩ | ១/៦/២០ |
| | | | ទម្លាក់គល់ឈើចំនួន ១០០គល់ចូលក្នុងកន្លែងអភិរក្សត្រីមេពូជ | ១៥០០ | ១/៣/១៩ | ១/៥/២០ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | សាងសង់ស្នាក់ការបណ្តែតទឹកដើម្បីការពារកន្លែងអភិរក្សត្រីមេពូជ | ១៥០០ | ១/៥/១៩ | ១/៧/២០ |

គ៣-ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះ/ទីតាំង | ទំហំ (ហ.ត) | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ប៉ាន់ស្មានតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| នាទីព្រៃលិចទឹកព្រែកផុកនៅតាមបណ្តោយមាត់ព្រែកផុក | ៥ | ដើមរាំង រំដេញ សណ្តាន់ ត្រស់ ប្របួយ ភ្នំភ្លើង | កំណត់ និងបោះបង្គោលព្រំប្រទល់នាទីព្រៃលិចទឹក ដែលត្រូវដាំ និងការពារ អភិរក្ស | ១០០០ | ១/២/១៩ | ២០២១ |
| | | | ធ្វើទិវាដាំព្រៃលិចទឹក ចំនួន៥០០០ដើម | ២៥០០ | ១/៣/១៩ | ២០២១ |
| | | | ធ្វើស្លាកសញ្ញាអភិរក្សព្រៃលិចទឹក ៤ផ្ទាំង | ២០០ | ១/៣/១៩ | ២០២១ |
| | | | ធ្វើទិវាអភិរក្ស ដើម្បីផ្សព្វផ្សាយអំពីគុណតម្លៃ និងការគ្រប់គ្រងព្រៃលិចទឹក | ៥០០ | ១/២/១៩ | ២០២១ |
| នាទីព្រៃលិចទឹកព្រែកជីឡែងនៅតាមបណ្តោយមាត់ព្រែកជីឡែង | ៥ | ដើមរាំង រំដេញ សណ្តាន់ ត្រស់ ប្របួយ ភ្នំភ្លើង | កំណត់ និងបោះបង្គោលព្រំប្រទល់នាទីព្រៃលិចទឹក ដែលត្រូវដាំ និងការពារ អភិរក្ស | ១០០០ | ១/២/១៩ | ២០២១ |
| | | | ធ្វើទិវាដាំព្រៃលិចទឹក ចំនួន៥០០០ដើម | ២៥០០ | ១/៣/១៩ | ២០២១ |
| | | | ធ្វើស្លាកសញ្ញាអភិរក្សព្រៃលិចទឹក ៤ផ្ទាំង | ២០០ | ១/៣/១៩ | ២០២១ |
| | | | ធ្វើទិវាអភិរក្ស ដើម្បីផ្សព្វផ្សាយអំពីគុណតម្លៃ និងការគ្រប់គ្រងព្រៃលិចព្រៃលិចទឹក | ៥០០ | ១/២/១៩ | ២០២១ |

គ៤-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំឡើង ដូចខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | ចំនួនគ្រួសារ | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីក្នុងបែ | ៦០ | ត្រីប្រា | ១៤៤០០០កូនត្រី | ១/៣/២០១៩ | ១/៦/២០២០ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ៥០ | ត្រីអណ្តែង | ២៨០០០កូនត្រី | ១/៤/២០១៩ | ១/៦/២០២០ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ៥០ | កង្កែប | ៤០០០០កូនកង្កែប | ១/៤/២០១៩ | ១/៩/២០២០ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ៥០ | អន្ទង់ដំណើប | ២៨០០០កូនអន្ទង់ | ១/១/២០១៩ | ១/១០/២០២០ |

គ៥-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំចាប់បញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | -ផ្សព្វផ្សាយអំពីភារកិច្ច និងផលប្រយោជន៍នៃការចូលជាសមាជិកស.ន<br>-រៀបចំបញ្ជីគណនេយ្យ<br>-ប្រមូលប្រាក់ភាគទានសុំចូលជាសមាជិកស.នចាស់ និងថ្មី | ១/១/១៩ | ១/១/២១ | ១២៥ | ១០០០រ/១នាក់ សមាជិកចាស់/ថ្មី អាច៥០០នាក់ រយៈពេល៣ឆ្នាំ |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយអំពីការបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំ | ១/១/១៩ | ១/១/២១ | ១៥០០ | -២០០០០រ ៖សមាជិកធ្វើនេសាទជាអាជីព<br>-៥០០០រ ៖សមាជិកធ្វើនេសាទម្តងម្កាល<br>-១០០០រ ៖ ចំពោះសមាជិកគាំទ្រមិនធ្វើនេសាទ<br>-...រ? ៖ មិនមែនជាសមាជិកស.នតែធ្វើនេសាទជាអាជីព |
| -ជំនួយសប្បុរសជន<br>-អង្គការនានា<br>-ជំនួយរាជរដ្ឋាភិបាល | -រៀបចំសរសេរគម្រោងស្នើសុំថវិកា និងស្វែងរកអង្គការដៃគូអភិវឌ្ឍន៍នានា<br>-ធ្វើគម្រោងផែនការស.នសុំដាក់បញ្ចូលសមាហរណកម្មក្នុងផែនការអភិវឌ្ឍន៍ឃុំ | ១/១/១៩ | ១/១/២១ | ៣៤៥០០ | ១១៥០០ដុល្លារ/ឆ្នាំ |
| | | | គម្រោងថវិកាសរុប | ៣៦១២៥$ | រយៈពេល៣ឆ្នាំ |

## គ៦-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល

ផែនការល្បាតទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | គោលបំណង | អ្នកចូលរួមអនុវត្តន៍ | ប៉ាន់ស្មានតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ទិញទូកស្ពាច់០២គ្រឿង ប្រវែង៨ម៉ែត្រ និងម៉ាស៊ីនទូកកម្លាំង១៧សេះ | ចុះល្បាតការពារនិងទប់ស្កាត់បទល្មើសជលផល ក្នុងកន្លែងនេសាទស.ន | - គណកម្មការនិង<br>- ក្រុមល្បាតសហគមន៍ស.ន | ២៥០០ | ២០១៩ | ២០២១ |
| ទិញឧបករណ៍សម្ភារៈសម្រាប់ចុះល្បាត( អាវពោងសុវត្ថិភាព អាគុយ អំពូលភ្លើងហ្វា ទូរស័ព្ទ វិទ្យុទាក់ទង ម៉ាស៊ីនថត ពិល អាវភ្លៀង កែវយឺត មេក្រូ ប្រេងសាំង ប្រេងម៉ាស៊ីន,..។ | ប្រើប្រាស់សម្រាប់ចុះល្បាត តាមដាន ត្រួតពិនិត្យ ទប់ស្កាត់បទល្មើសជលផលក្នុងកន្លែងនេសាទស.ន | - គណកម្មការនិង<br>- ក្រុមល្បាតសហគមន៍ស.ន | ១០០០ | ២០១៩ | ២០២១ |
| រៀបចំក្រុមល្បាត និងបែងចែកតាមវេនចុះល្បាតប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ | ឲ្យមានក្រុម និងវេនចុះល្បាតឲ្យបានទៀងទាត់ជាប្រចាំ | - គណកម្មការនិង<br>- ក្រុមល្បាតសហគមន៍ស.ន | ៧០០ | ២០១៩ | ២០២១ |
| -ផ្សព្វផ្សាយតាមមេក្រូ៦ដង/ឆ្នាំ<br>-បិទលិខិតបទដ្ឋានគតិយុត្តផ្សព្វផ្សាយចំនួន២ដង/ឆ្នាំ | បង្កើនការយល់ដឹងអំពីឧបករណ៍នេសាទស្របច្បាប់ ឧបករណ៍នេសាទហាមឃាត់ និងការពារកន្លែងអភិរក្សត្រីមេពូជ | - គណកម្មការនិង<br>- ក្រុមល្បាតសហគមន៍ស.ន<br>- អាជ្ញាធរភូមិ ឃុំ | ៣០០ | ២០១៩ | ២០២១ |

## គ៧-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ

ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| វគ្គបណ្តុះបណ្តាល និងទិវាអភិរក្ស | គោលបំណង | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ក. វគ្គបណ្តុះបណ្តាល | | | | |
| ច្បាប់ស្តីពីជលផល អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងស.ន | បង្កើនយល់ដឹងអំពីខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលជលផល | -គណកម្មការ និងសមាជិកសហគមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| ជំនាញសម្របសម្រួល និងជំនាញដោះស្រាយទំនាស់ | មានចំណេះដឹងក្លាយជាអ្នកសម្របសម្រួល និងចេះដោះស្រាយទំនាស់បានល្អ | -គណកម្មការ និងសមាជិកសហគមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |

| | | | | |
|---|---|---|---|---|
| របៀបសរសេរលិខិតរដ្ឋបាល(របាយការណ៍ និងកំណត់ហេតុ) | មានចំណេះដឹងអំពីសរសេរ និងគ្រប់គ្រងលិខិតរដ្ឋបាល | -គណកម្មការ និងសមាជិកសហ-គមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| របៀបរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងធ្វើផែនការអនុវត្តន៍សកម្មភាពគម្រោង | មានចំណេះដឹងអំពីរបៀបធ្វើផែនការសហគមន៍ និងផែនអនុវត្តន៍សកម្មភាពគម្រោង | -គណកម្មការ និងសមាជិកសហ-គមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| របៀបសរសេរគម្រោងស្នើសុំថវិកា និងធ្វើផែនការគ្រប់គ្រងថវិកាស.ន និងរបៀបស្វែងរកថវិកា | មានចំណេះដឹងអំពីរបៀបសរសេរគម្រោងស្នើសុំថវិកា និងការធ្វើផែនការគ្រប់គ្រង និងយុទ្ធសាស្ត្រស្វែងរកថវិកា | -គណកម្មការ និងសមាជិកសហ-គមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| - កសាងភាពជាដៃគូ និងបណ្តាញ<br>- ភាពជាអ្នកដឹកនាំ | -មានចំណេះដឹងអំពីសារៈប្រយោជន៍កសាងភាពជាដៃគូ និងបណ្តាញ<br>-ក្លាយទៅជាអ្នកដឹកនាំស.នល្អ | -គណកម្មការ និងសមាជិកសហ-គមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| ប្រភេទនៃអ្នកចូលរួមក្នុងការអភិវឌ្ឍ | មានចំណេះដឹងអំពីការជ្រើសរើស និងធ្វើការជាមួយអ្នកចូលរួមពិតប្រាកដក្នុងការអភិវឌ្ឍសហគមន៍មូលដ្ឋាន | -គណកម្មការ និងសមាជិកសហ-គមន៍នេសាទ<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| **ខ. ទិវាអភិរក្ស និងផ្សព្វផ្សាយ** | | | | |
| ការបង្កើត និងសារប្រយោជន៍នៃការគ្រប់គ្រងកន្លែងអភិរក្សត្រីមេពូជ | ឲ្យមានការចូលរួមពីសមាជិកស.ន និងប្រជាពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ លេងល្បែងប្រាជ្ញា និងផ្សព្វផ្សាយអំពីការបង្កើត និងសារៈប្រយោជន៍នៃកន្លែងអភិរក្ស | -គណកម្មការស.ន<br>-សមាជិកសហ-គមន៍នេសាទ<br>-មិនមែនសមា-ជិកសហគមន៍<br>-អាជ្ញាធរភូមិ ឃុំ ប្រជាពលរដ្ឋទូទៅ | ២០១៩ | ២០២១ |
| គុណតម្លៃនៃព្រៃលិចទឹក និងនិងការគ្រប់គ្រងព្រៃលិចទឹក | ឲ្យមានការចូលរួមពីសមាជិកស.ន និងប្រជាពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ លេងល្បែងប្រាជ្ញា និងផ្សព្វផ្សាយអំពីគុណតម្លៃ និងការគ្រប់គ្រងព្រៃលិចទឹក | -គណកម្មការស.ន<br>-សមាជិកសហ-គមន៍នេសាទ<br>-មិនមែនសមា-ជិកសហគមន៍<br>-អាជ្ញាធរភូមិ ឃុំ<br>-ប្រជាពលរដ្ឋទូទៅ | ២០១៩ | ២០២១ |
| ការធ្វើនេសាទប្រកបដោយនិរន្តរភាពក្នុងកន្លែងនេសាទសហគមន៍ | ឲ្យមានការចូលរួមពីសមាជិកស.ន និងប្រជាពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ | -គណកម្មការស.ន<br>-សមាជិកសហ-គមន៍ស.ន<br>-មិនមែនសមា- | ២០១៩ | ២០២១ |

| | | | | |
|---|---|---|---|---|
| | លេងល្បែងប្រាជ្ញា និងផ្សព្វផ្សាយអំពីការធ្វើនេសាទប្រកបដោយនិរន្តរភាព | ជិកសហគមន៍<br>-អាជ្ញាធរភូមិ ឃុំ<br>-ប្រជាពលរដ្ឋមូលដ្ឋាន | | |
| ផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍នេសាទ | ឲ្យមានការចូលរួមពីសមាជិក ស.ន និងប្រជាពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ លេងល្បែងប្រាជ្ញា និងផ្សព្វផ្សាយអំពីផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍ | -គណកម្មការ<br>-សមាជិកសហគមន៍ស.ន<br>-មិនមែនសមាជិកស.ន<br>-អាជ្ញាធរភូមិ ឃុំ<br>-ប្រជាពលរដ្ឋមូលដ្ឋាន | ២០១៩ | ២០២១ |

ឃ- ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកស្វែងថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំផែនការអនុវត្តតាមដំណាក់កាលនិមួយៗដោយជាក់លាក់ និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូអភិវឌ្ឍន៍សម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍នេសាទ
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍឃុំ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បារ៉ាយរុងរឿង រយៈពេល ៣ឆ្នាំ (២០១៩ដល់២០២១)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ប្រជុំពិគ្រោះយោបល់អំពីការប្រើប្រាស់ឧបករណ៍នេសាទឲ្យសមស្រប និងកំណត់ទីកន្លែងនេសាទឲ្យបានច្បាស់លាស់ | -ធ្វើនេសាទប្រកបដោយនិរន្តរភាព<br>-បង្កើនប្រាក់ចំណូលពីផលនេសាទ<br>-ធនធានជលផលកើនឡើង | ៣០០០ | -សមាជិកសហគមន៍ និងគណកម្មការស.ន<br>-អាជ្ញាធររដ្ឋបាលឃុំ | ២០១៩ | ២០២១ | |
| គ២-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស | បោះបង្គោលស៊ីម៉ងត៍ចំនួន២៦ដើមដាក់ព័ទ្ធជុំវិញកន្លែងអភិរក្សទំហំ១ហិកតា (200មX50ម) | -មានព្រំប្រទល់កន្លែងអភិរក្សត្រីមេពូជ<br>-បែងចែកបានច្បាស់លាស់រវាងកន្លែងនេសាទ និងកន្លែងអភិរក្សត្រីមេពូជ | ៣១២០ | -រាជរដ្ឋាភិបាលតាមរយៈ មន្ទីរកសិកម្មខេត្ត ឬរដ្ឋបាលជលផលឬអាជ្ញាធររដ្ឋបាលឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នេសាទ<br>-សប្បុរសជន | ១/៣/១៩ | ១/៥/២០ | |
| | ធ្វើស្លាកសញ្ញាអភិរក្សចំនួន៤ផ្ទាំងដាក់នៅជាប់ព្រំប្រទល់កន្លែងអភិរក្ស | មានសញ្ញាសម្គាល់អំពីហាមឃាត់ចូលធ្វើនេសាទ និងហាមបើកបរទូកឆ្លងកាត់ខាងក្នុងកន្លែងអភិរក្សត្រីមេពូជ | ៤០០ | | ១/៤/១៩ | ១/៦/២០ | |
| | ទម្លាក់គល់ឈើចំនួន ១០០គល់ចូលក្នុងកន្លែងអភិរក្សត្រីមេពូជ | មានជម្រកសប្បនិម្មិតត្រីមេពូជសម្រាប់រស់នៅជំលូតលាស់បន្តពូជពងកូន និងការពារមិនឲ្យលួចនេសាទ | ១៥០០ | | ១/៣/១៩ | ១/៥/២០ | |
| | សាងសង់ស្នាក់ការបណ្តែតទឹកដើម្បីការពារកន្លែងអភិរក្សត្រីមេពូជ | មានស្នាក់ការបណ្តែតទឹកសម្រាប់យាមល្បាត ការពារមិនឲ្យចូលនេសាទក្នុងកន្លែងអភិរក្សត្រីមេពូជ និងទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទហាមឃាត់ | ១៥០០ | | ១/៥/១៩ | ១/៧/២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៣-ផែនការគ្រប់គ្រងព្រៃលិចទឹក | កំណត់ និងបោះបង្គោលព្រំប្រទល់នាទីព្រៃលិចទឹកដែលត្រូវដាំ និងការពារអភិរក្សព្រៃលិចទឹកនៅតាមបណ្តោយមាត់ព្រែកផុក និងព្រែកជីឡែង | មានព្រំប្រទល់កន្លែងអភិរក្សព្រៃលិចទឹកច្បាស់លាស់ | ២០០០ | | ១/២/១៩ | ២០២១ | |
| | ធ្វើទិវាដាំព្រៃលិចទឹកចំនួន១០០០០ដើម | ត្រូវបានដាំកូនដើមព្រៃលិចទឹក(រាំងរំដេញ សណ្តាន់ ត្រស់ ប្របួយ ភ្នំភ្លើង) ក្នុងនៅទំហំដីលិចទឹក១០ហិកនៅតាមមាត់ព្រែកផុក និងព្រែកជីឡែង។ | ៥០០០ | | ១/៣/១៩ | ២០២១ | |
| | ធ្វើស្លាកសញ្ញាអភិរក្សចំនួន៨ផ្ទាំងសម្រាប់ការពារ អភិរក្សព្រៃលិចទឹកនៅតាមបណ្តោយមាត់ព្រែកផុក និងព្រែកជីឡែង | មានសញ្ញាហាមឃាត់ការកាប់ទន្រ្ទានឈូសឆាយបំផ្លាញនាទីព្រៃលិចទឹក | ៨០០ | | ១/៣/១៩ | ២០២១ | |
| | ធ្វើទិវាអភិរក្សដើម្បីផ្សព្វផ្សាយអំពីគុណតម្លៃ និងការគ្រប់គ្រងព្រៃលិចទឹក | សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋមូលដ្ឋានបានយល់ដឹងអំពីគុណតម្លៃនៃព្រៃលិចទឹក និងចូលរួមយ៉ាងសកម្មការពារ អភិរក្សព្រៃលិចទឹក។ | ១០០០ | | ១/២/១៩ | ២០២១ | |
| គ៤-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | -បើកវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈពាណិជ្ជកម្មនៅក្នុងបែ ស្រះ និង និងតង់កៅស៊ូ។ | សមាជិកសហគមន៍នេសាទចំនួនប្រហែល២០០គ្រួសារមានចំណេះដឹងបច្ចេកទេសចិញ្ចឹមត្រីលក្ខណៈពាណិជ្ជ-កម្មនៅក្នុងបែ ស្រះ និងតង់កៅស៊ូ។ | ៨០០០ | | ១/៥/១៩ | ១/៥/២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៥-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | -ផ្សព្វផ្សាយអំពីភារកិច្ច និងផលប្រយោជន៍នៃការចូលជាសមាជិកសហគមន៍<br>-ប្រមូលការបង់ប្រាក់ភាគទានសុំចូលជាសមាជិក ស.ន និងអ្នកសុំចូលថ្មី<br>-ធ្វើគម្រោងស្នើសុំថវិកា និងស្វែងរកអង្គការដៃគូអភិវឌ្ឍន៍នានា<br>-ធ្វើគម្រោងផែនការគ្រប់គ្រងកន្លែងនេសាទស.ន សម្រាប់សុំដាក់បញ្ចូលសមាហរណកម្មក្នុងផែនការអភិវឌ្ឍន៍ឃុំ | ទទួលបានថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍តាមគម្រោងផែនការ | ៣៦១២៥ | -សមាជិក និងមិនមែនសមាជិកសហគមន៍ស.ន<br>-រាជរដ្ឋាភិបាលតាមរយៈមន្ទីរកសិកម្មខេត្ត ឫរដ្ឋបាលជលផលឫអាជ្ញាធររដ្ឋបាលឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នេសាទ<br>-សប្បុរសជន | ១/១/១៩ | ១/១/២១ | |
| គ៦-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល | -ទិញទូកស្នាច់០២គ្រឿង ប្រវែង៨ម៉ែត្រនិងម៉ាស៊ីនទូកមានកម្លាំង១៧សេះ<br>-ទិញឧបករណ៍សម្ភារៈសម្រាប់ចុះល្បាត<br>-រៀបចំក្រុមល្បាត និងបែងចែកវេនចុះល្បាត<br>-ផ្សព្វផ្សាយតាមមេក្រូ៦ដងក្នុងមួយឆ្នាំ និងបិទលិខិតបទដ្ឋានគតិយុត្ត ផ្សព្វផ្សាយ២ដងក្នុងមួយឆ្នាំ | -មានទូកម៉ាស៊ីន និងឧបករណ៍សម្ភារៈសម្រាប់ចុះល្បាត ទប់ស្កាត់បទល្មើស<br>-ប្រជានេសាទទូទៅ និងសមាជិកសហគមន៍នេសាទបានយល់ដឹងអំពីការប្រើប្រាស់ឧបករណ៍នេសាទស្របច្បាប់ នៅក្នុងកន្លែងសហគមន៍នេសាទ និងបទល្មើសនេសាទថយចុះ | ៤៥០០ | -រាជរដ្ឋាភិបាលតាមរយៈមន្ទីរកសិកម្មខេត្ត ឫរដ្ឋបាលជលផលឫអាជ្ញាធររដ្ឋបាលឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នេសាទ<br>-សប្បុរសជន | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ៧-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ | -បណ្ដុះបណ្ដាលអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសហគមន៍នេសាទ និងពង្រឹងសមត្ថភាពគណៈកម្មការ និងសមាជិកស.ន។<br>-ធ្វើទិវាអភិរក្ស និងផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ និងលេង ល្បែងប្រាជ្ញា ដែលទាក់ទងកន្លែងអភិរក្សត្រីមេពូជ ព្រៃលិចទឹក និងផលប្រយោជន៍នៃការចូលរួមក្នុងស.ន។ | - គណកម្មការ និងសមាជិកសហគមន៍បានយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសហគមន៍នេសាទ និងមានសមត្ថភាពក្លាយជាអ្នកដឹកនាំល្អ ឬជាគ្រូបង្គោលក្នុងសហគមន៍មូលដ្ឋាន<br>- សមាជិកសហគមន៍ និងប្រជាពលរដ្ឋមូលដ្ឋានបានយល់ដឹងអំពីសារប្រយោជន៍នៃកន្លែងអភិរក្សត្រីមេពូជ ព្រៃលិចទឹក និងផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍នេសាទ។ | ៣០០០ | -រាជរដ្ឋាភិបាលតាមរយៈមន្ទីរកសិកម្មខេត្ត ឬរដ្ឋបាលជលផលឬអាជ្ញាធររដ្ឋបាលឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នេសាទ<br>-សប្បុរសជន | ២០១៩ | ២០២១ | |

# តារាងកម្មវិធីការងារ

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | | | | | | | ២០២០ | | | ២០២១ | | |
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | ... | ធ្នូ | មករា | ... | ធ្នូ |
| គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ២- ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស | | | → | → | → | → | → | | | | | | → | | | | | |
| គ៣- ផែនការគ្រប់គ្រងព្រៃលិចទឹក | | → | → | → | → | → | | | | | | | → | → | | → | → | |
| គ៤- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | → | → | → | → | → | → | → | → | → | ⇢ | ⇢ | ⇢ | ⇢ | ⇢ |
| គ៥- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ៦- ផែនការល្បាតទប់ស្កាត់បទល្មើសជលផល | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| គ៧- ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |

បានឃើញ និងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ........ ខែ........ ឆ្នាំ........ ស័ក ព.ស២៥៦២
ត្បូងឃ្មុំ ថ្ងៃទី២៣ ខែ........ ឆ្នាំ២០១៨
នាយផ្នែករដ្ឋបាលជលផលត្បូងឃ្មុំ
[illegible]

លេខ : 155/18 ........
បានឃើញ និងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលត្បូងឃ្មុំ
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ........ ខែ........ ឆ្នាំ........ ស័ក ព.ស២៥៦២
ឈូក ថ្ងៃទី 08 ខែ........ ឆ្នាំ២០១៨
មេឃុំឈូក
យឹន_ផុន

សូមគោរពជូន
លោកមេឃុំឈូក
"ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ........ ខែ........ ឆ្នាំ........ ស័ក ព.ស២៥៦២
បារាំយ ថ្ងៃទី ០២ ខែ........ ឆ្នាំ២០១៨
ប្រធានគណៈកម្មការសហគមន៍នេសាទបារាំយរុងរឿង
[illegible]

លេខ :..........

បានឃើញ និងគោរពជូន

លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ.......... ខែ..........ឆ្នាំ..........ស័ក ព.ស២៥៦២

ត្បូងឃ្មុំ ថ្ងៃទី ២៣ខែ..........ឆ្នាំ២០១៨

នាយខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ

**អៀម_ម៉ាយ៉ុងរី**

លេខ :..........

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃ..........ខែ..........ឆ្នាំ..........ស័ក ព.ស២៥៦២

ត្បូងឃ្មុំ ថ្ងៃទី២៦ ខែ..........ឆ្នាំ២០១៨

ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ

**ហេង ពិសិដ្ឋ**

លេខ :..........

<u>បានឃើញ និងឯកភាព</u>

ថ្ងៃ.......... ខែ..........ឆ្នាំ..........ស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ..........ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**